01739893

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

# គម្រោងបញ្ចប់ផែនការ

# កំណែលើកទី ១១

# ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦


**សេចក្តីសង្ខេប**....3
I. **សេចក្តីផ្តើម**....4
II. **វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស**....9
III. **ផែនការបញ្ចប់ការស៊ើបអង្កេត**....11
IV. **ផែនការបញ្ចប់សវនាការ**....17
ក. សំណុំរឿង០០២/០២....18
ខ. បទចោទដែលនៅសេសសល់/ការចោទប្រកាន់តាមអង្គហេតុ ក្នុងសំណុំរឿង០០២....20
គ. សំណុំរឿង០០៣ និង សំណុំរឿង០០៤....20
V. **ផែនការបញ្ចប់បណ្តឹងសាទុក្ខ**....21
ក. សំណុំរឿង០០២/០១....21
ខ. សំណុំរឿង០០២/០២....21
គ. សំណុំរឿង០០៣/០០៤....21
VI. **សេចក្តីសន្និដ្ឋាន**....22


ឧបសម្ព័ន្ធ ៖ តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ។

**សំគាល់៖**

គម្រោងបញ្ចប់ផែនការ អវតក ត្រូវបានកែសម្រួលរៀងរាល់មួយត្រីមាសម្តង ក្នុងគោលបំណងរៀបចំផែនការ។ មាតិកានៃគម្រោងនេះរួមមានការប៉ាន់ប្រមាណនូវពេលវេលាសម្រាប់សំណុំរឿងដែលនៅសេសសល់នៃ អ.វ.ត.ក គិតត្រឹមពេលនៃការកែសម្រួលនេះ។ កត្តាមួយចំនួន ក្នុងនោះរួមមានការវិវត្តនៃដំណើរការនីតិវិធី គឺអាចមានឥទ្ធិពលទៅលើការបាន់ប្រមាណទុកទាំងនេះ។ ហេតុដូច្នេះពេលវេលាដែលគ្រោងទុកទាំងឡាយមិនឆ្លុះបញ្ចាំងតម្រូវការតាមផ្លូវច្បាប់ទៅលើព្រឹត្តិការណ៍សំខាន់ខុសៗគ្នានឹងត្រូវសម្រេចនៅពេលណានោះឡើយ។

01739895

## សេចក្តីសង្ខេប

គម្រោងបញ្ចប់ផែនការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះ”) ត្រូវបានរៀបចំឡើងជាដំបូងនៅខែ មីនា ឆ្នាំ ២០១៤ ដោយឆ្លងកាត់ការពិគ្រោះពិភាក្សាយោបល់ពីសំណាក់ការិយាល័យរដ្ឋបាល ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះផ្សេងៗ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាទាក់ទិននឹងការទទួលខុសត្រូវរបស់ពួកគាត់។ នេះគឺជាការធ្វើបច្ចុប្បន្នភាពប្រចាំត្រីមាសទី ១១ នៃ គម្រោងបញ្ចប់ផែនការនេះដែលផុតនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦។ នៅក្នុងកំលុង ត្រីមាសទី២អង្គជំនុំជម្រះតុលាការកំពូលបានបន្តការពិភាក្សាសម្រេចធ្វើសេចក្តីព្រាងសាលដីកាបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ ដែលគ្រោងនឹងប្រកាសនៅត្រីមាសទី៣ ឆ្នាំ២០១៦។

នៅក្នុងត្រីមាសនេះ អង្គជំនុំជម្រះតុលាការកំពូល បានប្រកាសសាលដីកាលើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០១។ ប្រការនេះបានបញ្ចប់ដំណើរការនីតិវិធី ក្នុងសំណុំរឿង០០២/០១។

នៅក្នុងដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០២ សវនាការលើភស្តុតាងបានវិវត្តទៅមុខជាមួយនឹងប្រធានបទសវនាការចំនួន២ចុងក្រោយ ពោលគឺ លក្ខណៈនៃជម្លោះប្រដាប់អាវុធនិងតួនាទីរបស់ជនជាប់ចោទ ដែលពាក់ព័ន្ធទៅនឹងបទចោទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។ សវនាការលើភស្តុតាងចុងក្រោយរំពឹងថានឹងបញ្ចប់នៅត្រឹមត្រីមាសទី១ឆ្នាំ២០១៧។[1]

សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរប្រឆាំងនឹង អោ អាន ហើយបានបង្គាប់បំបែកដំណើរការនីតិវិធីលើ អោ អាន ពីសំណុំរឿង០០៤ និងបង្កើតសំណុំរឿងមួយទៀត គឺ ០០៤/០២។

លំហូរនៃគម្រោងបញ្ចប់ផែនការនេះត្រូវបានធ្វើបច្ចុប្បន្នភាព ក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពនៃដំណើរការនីតិវិធីតុលាការគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។

[1] អង្គជំនុំជម្រះបានបញ្ចប់សវនាការលើភស្តុតាងនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ (សូមមើលសេចក្តីប្រកាសព័ត៌មានក្នុងកាលបរិច្ឆេទដូចគ្នា)។

01739896

## I. សេចក្តីផ្តើម

១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានចាប់ផ្តើមដំណើរការរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរពេញលេញបន្ទាប់ពីការអនុម័តវិធានផ្ទៃក្នុងនៅក្នុងខែមិថុនា ឆ្នាំ២០០៧។ អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីកាត់សេចក្តី “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ១៩៧៩”[2]។

២ គម្រោងបញ្ចប់ផែនការនេះបានបរិយាយយ៉ាងលម្អិតដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងបរិបទនៃសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ A/RES/68/247B ដែលក្នុងចំណោមបញ្ហាផ្សេងៗទៀត បានកំណត់អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញឲ្យរៀបចំយុទ្ធសាស្ត្របញ្ចប់ ដោយមានផែនទីបង្ហាញផ្លូវច្បាស់លាស់មួយ[3]។ ឯកសារនេះធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញដោយមានការពិគ្រោះយោបល់តាមរយៈការិយាល័យរដ្ឋបាលជាមួយចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអំពីការទទួលខុសត្រូវរបស់ពួកគេ។ អង្គជំនុំជម្រះវិសាមញ្ញ ធ្វើបច្ចុប្បន្នភាពផែនការបញ្ចប់នេះរៀងរាល់ត្រីមាស។ ឯកសារនេះគឺជាកំណែលើកទី១១ ប្រចាំត្រីមាសនៃគម្រោងបញ្ចប់ផែនការ ហើយបានបញ្ចូលនូវការកែតម្រូវដែលចាំបាច់នានា ដោយផ្អែកលើការវិវត្តនៃដំណើរការនីតិវិធីតាមផ្លូវតុលាការដែលកំពុងប្រព្រឹត្តទៅក្នុងរវាងថ្ងៃទី ១ ខែ តុលា ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦។

---

[2] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[3] នៅក្នុងសេចក្តីសម្រេចដដែលនោះ មហាសន្និបាត អ.ស.ប បានស្នើឲ្យមាន “ការពិនិត្យយ៉ាងម៉ត់ចត់ទៅលើការផ្តល់ហិរញ្ញប្បទានសម្រាប់ អ.វ.ត.ក នៅពេលអនាគតសម្រាប់ឆ្នាំ ២០១៥ និងឆ្នាំខាងមុខទៀត”។ សូមមើលសេចក្តីសម្រេចលេខ A/RES/68/247B ដែលអនុម័តដោយមហាសន្និបាត អ.ស.ប នៅថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៤។ “កម្មវត្ថុពិសេសនានាទាក់ទិននឹងថវិកាសម្រាប់កម្មវិធីរយៈពេល២ឆ្នាំម្តង ២០១៤-២០១៥” B, I, កថាខណ្ឌទី៨។

៣ ឯកសារនេះផ្តោតជាពិសេសលើការវិវត្តន៍នាពេលថ្មីៗនេះ នៅក្នុងសំណុំរឿងដែលនៅសេសសល់ទាំងបី ដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខ អ.វ.ត.ក និងផ្តល់នូវព័ត៌មានអំពីប្រភេទនៃរឿងក្តី ព្រមទាំងស្ថានភាពនៃសំណុំរឿងទាំងនោះ ព្រមទាំងជំហាននានាដែលត្រូវបំពេញ មុនពេលកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការទាក់ទិននឹងសំណុំរឿងកំពុងរង់ចាំបច្ចុប្បន្ននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ បញ្ចប់ជាស្ថាពរតាមផ្លូវច្បាប់។ សហព្រះរាជអាជ្ញាបានថ្លែងជាសាធារណៈថា នឹងពុំមានសំណុំរឿងបន្ថែមទៀតទេបន្ទាប់ពីសំណុំរឿង ០០៣ និង ០០៤[4]។ ហេតុនេះ សំណុំរឿងដែលមាននាពេលនេះគឺជាសំណុំរឿងសរុបដែល អ.វ.ត.ក ត្រូវចាត់ការតាមនីតិវិធី។

៤ សំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្គេចអ៊ាវ (ហៅ ឌុច) គឺជាសំណុំរឿងដំបូងដែលជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះ អ.វ.ត.ក ។ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសសាលដីការបស់ខ្លួននៅក្នុងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលធ្វើឲ្យសំណុំរឿងនេះត្រូវបានបញ្ចប់ស្ថាពរ។ កាំង ហ្គេចអ៊ាវ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

៥ មកដល់ពេលនេះអង្គជំនុំជម្រះបានបំបែកបទចោទនៅក្នុងសំណុំរឿង ០០២ ទៅជាសវនាការតូចៗចំនួនពីរ ។ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមនៅក្នុងសវនាការដំណាក់កាលទីមួយ ដែលអង្គជំនុំជម្រះវិសាមញ្ញកំណត់ឈ្មោះ សំណុំរឿងថា សំណុំរឿង០០២/០១ នៅថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០១៤ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន។ ជនជាប់ចោទពីរនាក់ទៀតនៅក្នុងរឿងក្តី គឺ អៀង សារី និង អៀង ធីរិទ្ធ បានទទួលមរណភាពនៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៥ ហេតុនេះហើយ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងពួកគេត្រូវបានរំលត់។ អង្គជំនុំជម្រះសាលា

---

[4] សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី៖ អំពីការដាក់ជូននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីៗ ចំនួន ២ ចេញផ្សាយថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៩ (www.eccc.gov.kh/sites/default/files/media/ECCC_Act_Int_Co_Prosecutor_8_Sep_2009_(Eng).pdf)។ សេចក្តីថ្លែងការណ៍សាធារណៈដោយសហព្រះរាជអាជ្ញាទាក់ទិននឹងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ចេញផ្សាយថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១២ (www.eccc.gov.kh/sites/default/files/media/ECCC%20OCP%205%20June%202012%20En.pdf) និងសេចក្តីថ្លែងការណ៍ដោយសហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងបន្ទុកការងាររបស់ អ.វ.ត.ក ចេញផ្សាយថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (http://www.eccc.gov.kh/en/articles/statement-international-co-prosecutor-regarding-eccc-caseload)។

01739898

ដំបូងបានរកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៧ និងត្រូវបានផ្តន្ទាទោសម្នាក់ៗឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ទាំង នួន ជា និង ខៀវ សំផន បានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសាលាដំបូង ។ សហព្រះរាជអាជ្ញាក៏បានដាក់ បណ្តឹងសាទុក្ខកម្រិតត្រឹមតែស្នើសុំសេចក្តីប្រកាសជាប្រយោជន៍ទៅលើការអនុវត្តទម្រង់ទូលាយ បំផុត នៃសហឧក្រិដ្ឋកម្មរួមដែលហៅថា JCE III ជាទម្រង់ទទួលខុសត្រូវមួយនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ ដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿងនេះត្រូវបានបញ្ចប់នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយមានការប្រកាសសាលដីកាអង្គជំនុំជម្រះតុលាការកំពូល និងបិទផ្លូវតវ៉ា។ អង្គជំនុំជម្រះតុលាការកំពូលតម្កល់សាលក្រមសាលាដំបូងដែលផ្តន្ទាទោសជនជាប់ចោទទាំងពីរដាក់ពន្ធនាគារអស់មួយ ជីវិត។

៦ ការជំនុំជម្រះទីពីរកំពុងដំណើរការក្នុងពេលបច្ចុប្បន្ននេះ ដែលអង្គជំនុំជម្រះវិសាមញ្ញដាក់ឈ្មោះថា សំណុំរឿង ០០២/០២ គឺផ្តោតលើជម្រើសតំណាងបទចោទមួយចំនួនដែលនៅសល់ប្រឆាំងនឹងជនជាប់ចោទទាំងពីរនាក់។ បទចោទទាំងនោះរួមមាន៖ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លើប្រធានបទ ការប្រព្រឹត្តិលើជនជាតិចាម វៀតណាម និង ពុទ្ធសាសនិក អាពាហ៍ពិពាហ៍ដោយបង្ខំ រំលោភសេពសន្ថវៈ មន្ទីរសន្តិសុខ និង សហករណ៍ ។ សវនាការលើភស្តុតាង ចាប់ផ្តើមនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥។ នៅត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មសាក្សីចំនួន ១១៣ នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៤ នាក់ និងអ្នកជំនាញចំនួន៨នាក់។ ការបញ្ចប់សវនាការលើភស្តុតាងដែលគ្រោងបញ្ចប់នៅខែធ្នូ ឆ្នាំ២០១៦ ឥឡូវត្រូវគ្រោងបញ្ចប់នៅត្រីមាសទី១ឆ្នាំ២០១៧។ បន្ទាប់មកនឹងមានការដាក់សារណាបញ្ចប់ការដេញដោលរបស់ភាគី នៅត្រឹមថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ ហើយសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនឹងចាប់ផ្តើមនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧។

៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបន្តស៊ើបអង្កេតសំណុំរឿង០០៣ និង ០០៤ ពាក់ព័ន្ធនឹងការចោទប្រកាន់លើជនត្រូវចោទចំនួន៤នាក់។ កិច្ចស៊ើបសួរលើ អ៊ឹម ចែម ក្នុងសំណុំរឿង០០៤ បានបញ្ចប់នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥។ សំណុំរឿងប្រឆាំងនឹង អ៊ឹម ចែម បន្ទាប់មកត្រូវបានបំបែកទៅជាសំណុំរឿង០០៤/០១ និងបញ្ជូនទៅពិនិត្យមូល។ ដីកាសន្និដ្ឋានពីអយ្យការនិងមេធាវីការពារក្តីត្រូវ

បានទទួល ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបច្ចុប្បន្នកំពុងពិភាក្សាសម្រេចទៅលើដីកាដំណោះស្រាយ ដែលរំពឹងថានឹងចេញនៅត្រីមាសទី១ឆ្នាំ២០១៧។ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងថាខ្លួនចាត់ទុកកិច្ចស៊ើបសួរលើ អោ អាន ក្នុងសំណុំរឿង០០៤ បានបានបញ្ចប់។ សហចៅក្រមស៊ើបអង្កេតក៏បានបង្គាប់ឲ្យបំបែកកិច្ចនីតិវិធីប្រឆាំងនឹង អោ អាន ក្នុងសំណុំរឿង០០៤ ហើយបង្កើតសំណុំរឿងថ្មីមួយទៀត គឺសំណុំរឿង០០៤/០២។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីសម្រេចដាច់ដោយឡែកមួយ ដោយកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរនៅក្នុងសំណុំរឿងនេះ អនុលោមតាមវិធាន៦៦ស្ទួន។ នេះជាលើកទីមួយហើយដែលវិធាននេះត្រូវបានយកមកអនុវត្ត។ ដីកាដំណោះស្រាយនៅក្នុងសំណុំរឿងនេះរំពឹងថានឹងចេញនៅត្រីមាសទី២ឆ្នាំ២០១៧។ ការស៊ើបអង្កេតប្រឆាំងនឹងជនត្រូវចោទទី៣ ក្នុងសំណុំរឿង០០៤ (យឹម ទិត្យ) នៅបើកចំហរនៅឡើយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបន្តកិច្ចស៊ើបសួរលើ មាស មុត ក្នុងសំណុំរឿង០០៣។ ការជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលរំពឹងថានឹងចេញនៅត្រីមាសទី៤ ឆ្នាំ២០១៦នោះ បច្ចុប្បន្នរំពឹងថានឹងចេញនៅត្រីមាសទី១ឆ្នាំ២០១៧[5]។

៨ តាមរយៈការវិវត្តន៍ក្នុងត្រីមាសចុងក្រោយនេះ គម្រោងបញ្ចប់ផែនការរបស់អង្គជំនុំជម្រះវិសាមញ្ញមានព្រឹត្តិការណ៍សំខាន់ចំនួន១១សម្រាប់សំណុំរឿងចំនួន៣ដែលអង្គជំនុំជម្រះនានាបានទទួល។ ព្រឹត្តិការណ៍សំខាន់ដែលនៅសេសសល់នៅក្នុងសំណុំរឿង០០២[6] និង ការព្យាករណ៍ ដែលពាក់ព័ន្ធគឺ៖

(i) ការបញ្ចប់សវនាការលើអង្គសេចក្តី ក្នុងសំណុំរឿង០០២/០២ (ត្រឹមត្រីមាសទី១ ឆ្នាំ២០១៧)។

(ii) សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី២ ឆ្នាំ២០១៧)។

(iii) ការចេញសាលក្រមនៅក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី៤ ឆ្នាំ២០១៧)។

---

[5] សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិចេញនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧។

[6] នៅក្នុងករណីដែលសំណុំរឿង០០២ ត្រូវបានបំបែកបន្ថែមទៀតតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅលើវិសាលភាពនៃសំណុំរឿង០០២/០២ ដែលរំពឹងថានឹងចេញនៅខែ មេសា ឆ្នាំ ២០១៤ វានឹងតម្រូវឲ្យមានសំណុំរឿង០០២/០៣។

(iv) ពេលវេលាកំណត់នៃការដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី១ ឆ្នាំ២០១៨) និង

(v) ការចេញសាលដីកានៅក្នុងសំណុំរឿង០០២/០២ ប្រសិនបើមាន (ត្រីមាសទី៣ ឆ្នាំ២០១៩)។

៩ នៅក្នុងសំណុំរឿង ០០៣ សំណុំរឿង០០៤ សំណុំរឿង០០៤/០១ និងសំណុំរឿង០០៤/០២ ព្រឹត្តិការណ៍ដាច់ដោយឡែក ត្រូវបានកំណត់សម្រាប់ដំណាក់កាលស៊ើបសួរ ដែលនៅសេសសល់ ហើយ ក្នុងករណីមានការចោទប្រកាន់នោះនឹងមានព្រឹត្តិការណ៍សំខាន់បន្ថែមទៀតសម្រាប់ដំណាក់កាលជំនុំជម្រះនិងបណ្តឹងសាទុក្ខ[7]។ ព្រឹត្តិការណ៍សំខាន់សម្រាប់ដំណាក់កាលស៊ើបអង្កេតដែលបន្តនៅសេសសល់ គឺៈ

(vi) សេចក្តីជូនដំណឹងអំពីការការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ (ត្រីមាសទី១ ឆ្នាំ២០១៧)។

(vii) សេចក្តីជូនដំណឹងអំពីការការបញ្ចប់កិច្ចស៊ើបសួរដែលនៅសេសសល់ក្នុងសំណុំរឿង០០៤ (ត្រីមាសទី១ ឆ្នាំ២០១៧) ។

(viii) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ជាមួយនឹងសេចក្តីសម្រេច ថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី២ ឆ្នាំ២០១៧)។

(ix) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤/០១ សំណុំរឿង០០៤/០២ និង សំណុំរឿង០០៤ ជាមួយនឹងសេចក្តី សម្រេចថា តើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី (នៅត្រីមាសទី១ ឆ្នាំ២០១៧ សម្រាប់ សំណុំរឿង០០៤/០១ និង ត្រីមាសទី២ សម្រាប់សំណុំរឿង០០៤/០២ និងត្រីមាសទី៣ ឆ្នាំ២០១៧ សម្រាប់សំណុំ រឿង០០៤។

(x) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះឬបញ្ចប់កិច្ចនីតិវិធីក្នុង សំណុំរឿងនោះ (ត្រីមាសទី៤ ឆ្នាំ២០១៧) ។

---

[7] ដោយសារស្ថានភាពនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន នៅពេលនេះយើងមិនអាច ព្យាករណ៍នូវចំណុចពេលវេលាជាក់លាក់ទាក់ទិននឹងគ្រោងការជំនុំជម្រះក្តីបានឡើយ។

(xi) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/០១ សំណុំរឿង០០៤/០២ និង សំណុំរឿង០០៤ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះឬបញ្ចប់ កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ(ត្រីមាសទី៣ ឆ្នាំ២០១៧ សម្រាប់សំណុំរឿង០០៤/០១ពាក់ព័ន្ធនឹង អ៊ឹម ចែម និង ត្រីមាសទី៤ ឆ្នាំ២០១៧ សម្រាប់សំណុំរឿងសំណុំរឿង០០៤/០២ ពាក់ព័ន្ធនឹង អោ អាន ហើយនៅត្រី មាសទី១ ឆ្នាំ២០១៨ សម្រាប់សំណុំរឿង០០៤ ពាក់ព័ន្ធនឹង យឹម ទិត្យ)។

## II. វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស

១០ ដំណើរការប្រកបដោយប្រសិទ្ធិភាពរបស់អង្គជំនុំជម្រះវិសាមញ្ញកន្លងទៅត្រូវបានរំខានដោយអសន្តិសុខផ្នែកហិរញ្ញវត្ថុដែលចេះតែបន្តកើតមាន ដែលបណ្តាលឲ្យបុគ្គលិកចំនួនពីររូបបានបោះបង់ការងារក្នុងអំឡុងឆ្នាំ២០១៣ ព្រមទាំងបុគ្គលិកចេញចូលពីមុខតំណែងដោយមិនសមហេតុផល។ ការអនុម័តរបស់មហាសន្និបាតទៅលើឧបត្ថម្ភធនសម្រាប់ឆ្នាំសារពើពន្ធ២០១៤-១០១៧សម្រាប់ភាគីអន្តរជាតិ នៃ អ.វ.ត.ក គឺជាវិធានការដ៏សំខាន់ដែលបានធ្វើឲ្យមានស្ថិរភាពដល់ស្ថានភាពថវិកានិងធ្វើឲ្យមានការផ្តោតមូលទៅលើការធ្វើឲ្យវិវត្តទៅមុខនៃអាណត្តិតុលាការ។ ប៉ុន្តែ ចំពោះភាគីជាតិវិញ ការលំបាកផ្នែកលំហូរសាច់ប្រាក់បាននាំឲ្យមានការពន្យារពេលបើកប្រាក់បៀវត្សសម្រាប់បុគ្គលិកជាតិនៅក្នុងកំលុងពាក់កណ្តាលឆ្នាំ២០១៥ ដែលប៉ះពាល់ដល់ការផ្តោតអារម្មណ៍ និងទឹកចិត្តបំពេញការងារ។

១១ ក្រោយពីមានការសម្រេចផ្តល់ការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ មហាសន្និបាតអង្គការសហប្រជាជាតិ ជាវិធានការពិសេស បាន អនុញ្ញាតឲ្យអគ្គលេខាធិការសម្រេចកំណត់ទឹកប្រាក់ចំនួនមិនលើសពី ១១ លានដុល្លារដើម្បី បន្ថែម បង្គ្រប់ធនធានថវិកាស្ម័គចិត្តរបស់ភាគីអន្តរជាតិ នៃ អ.វ.ត.ក សម្រាប់រយៈពេលគិតចាប់ពីថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។ សកម្មភាពទាន់ពេលវេលានេះនឹងជួយសម្រួលយ៉ាងសំខាន់ ដល់ប្រតិបត្តិការកុំឲ្យរអាក់រអួលនៅកំលុងឆមាសទី១ ឆ្នាំ២០១៧ ដោយបើកឱកាសឲ្យមានការរៃ អង្គាសថវិកា ស្ម័គ្រចិត្តបន្តទៀត។ ជាងនេះទៀត ការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់ វិភាគទានដោយផ្ទាល់ម្តងទៀតគិតត្រឹមឆ្នាំ២០១៦ ដើម្បីចំណាយទៅលើប្រាក់បៀវត្សបុគ្គលិកជាតិ៦ខែដំបូង ក៏ដូចជាចំណាយប្រតិបត្តិការសម្រាប់ឆ្នាំ២០១៧ គឺជាវិធានការដ៏សំខាន់ដែលជួយដល់ប្រតិបត្តិការ បច្ចុប្បន្ន របស់ភាគីជាតិនៃអ.វ.ត.ក។

01739902

ដោយរួមបញ្ចូលគ្នាបែបនេះ វិធានការទាំងនេះធានាថាដំណាក់ កាលដែលមានទំហំការងារច្រើនបំផុតបច្ចុប្បន្ននៅក្នុងកិច្ចការរបស់អ.វ.ត.ក គឺបន្តទទួលបាននូវការ យកចិត្តទុកដាក់ជានិច្ចឆ្ពោះទៅឆ្នាំ២០១៧។ ការប៉ាន់ស្មានលើតារាងកំណត់ពេលវេលាខាងក្រោម ត្រូវ បានធ្វើឡើងដោយផ្អែកមូលដ្ឋានថា អង្គជំនុំជម្រះនិងការិយាល័យទាំងអស់មានបុគ្គលិកគ្រប់គ្រាន់ និង ថាកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ នឹងមិនត្រូវរំខាន ដោយសារតែអសន្តិសុខផ្នែកហិរញ្ញវត្ថុ។ ប្រសិនបើអសន្តិសុខផ្នែកហិរញ្ញវត្ថុលេចឡើង យើងអាចចាំបាច់ត្រូវកែសម្រួលតារាងពេល វេលាឡើងវិញ។

១២ នៅខែមករា ឆ្នាំ២០១៥ កិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក បានអនុម័តវិសោធនកម្មទៅលើវិធាន ផ្ទៃក្នុងដែលអនុញ្ញាតឲ្យមានការកាត់បន្ថយទៅលើវិសាលភាពកិច្ចស៊ើបសួរល្គឹកណាវិសាលភាពស៊ើបអង្កេតដែលបានកាត់បន្ថយជាតំណាងឲ្យបទចោទ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសង្ស័យ តាមការចោទប្រកាន់[8]។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងអាចកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះក្តីដោយមិនរួមបញ្ចូលអង្គហេតុជាក់លាក់មួយចំនួនដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដរាបណាអង្គហេតុដែលនៅសល់ដែលត្រូវជម្រះ គឺជាតំណាងវិសាលភាពនៃដីកាបញ្ជូនរឿងទៅជម្រះ[9]។ បច្ចុប្បន្នអង្គជំនុំជម្រះសាលាដំបូងទទួលសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំបញ្ចប់កិច្ចនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុទាំងនោះ ដែលត្រូវបានដកចេញពីវិសាលភាពនៃសំណុំរឿង០០២/០២។ ប្រសិនបើទទួលបានការអនុញ្ញាត ការបញ្ចប់សំណុំរឿង០០២/០២ នឹងនាំដល់ការបញ្ចប់នីតិវិធីក្នុងសំណុំរឿង០០២/០២។

១៣ ក្នុងគោលបំណងបង្កើនសមត្ថភាពស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្រសួងយុត្តិធម៌ បានផ្តល់នីតិសម្បទាដល់មន្ត្រីច្បាប់អន្តរជាតិចំនួនប្រាំបួននាក់ ដើម្បីចុះធ្វើកំណត់ហេតុស្តាប់ចម្លើយហើយកិច្ចការនេះជាធម្មតាគឺត្រូវបំពេញដោយអ្នកស៊ើបអង្កេតប៉ុណ្ណោះ។ ការបង្កើនសមត្ថភាពក្នុងការចុះធ្វើកំណត់ហេតុស្តាប់ចម្លើយនេះ បានជំរុញឲ្យដំណាក់កាលស៊ើបសួរបានលឿន។ ជាងនេះទៀតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលលទ្ធផលពីធនធានមនុស្ស របស់ខ្លួនជាមួយនឹង

---

[8] វិធាន៦៦ស្ទួន អនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតមិនបញ្ចូលអង្គហេតុមួយចំនួនពីការស៊ើបសួរ ដរាបណាអង្គហេតុដែលនៅសល់មានលក្ខណៈគ្រប់គ្រាន់យកមកធ្វើជាតំណាងនៃវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ សិទ្ធិអំណាចនេះត្រូវបានយកមកអនុវត្តជាលើកដំបូងក្នុងខែធ្នូឆ្នាំ២០១៦ ក្នុងសំណុំរឿង០០៤/០២។

[9] វិធាន៨៩ស្ទួន៣។

បុគ្គលិកជំនាញក្រោមកម្មីដែលមិនត្រូវសងវិញ និងកម្មសិក្សាការីបន្ថែមទៀត ដែលបង្កើនលទ្ធផលនៃកិច្ចស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបន្តទាក់ទងរដ្ឋជាសមាជិក និង អង្គការវិជ្ជាជីវៈនានាក្នុងគោលបំណងជ្រើសរើសអ្នកស៊ើបអង្កេតបន្ថែមមកបំពេញការងារជាបុគ្គលិក មិនយកប្រាក់កម្រៃ។ ជាងនេះទៀត ការិយាល័យរដ្ឋបាលបានរក្សាសេវាកម្មរបស់បុគ្គលិកឯកទេសភាសាដើម្បីគាំទ្រដល់ការិយាល័យតុលាការដើម្បីធានាសេវាបកប្រែនិងប្រតិចារឹកបានទាន់ពេលវេលា។

## III. ផែនការបញ្ចប់ការស៊ើបអង្កេត

១៤ កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ ត្រូវបានផ្តួចផ្តើមឡើងក្រោយពីមានដីកាបញ្ជូនរឿងឲ្យស៊ើបសួរដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅខែកញ្ញា ឆ្នាំ២០០៩។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមមួយចំនួនទៀត។ សហចៅក្រមស៊ើបអង្កេតជាតិនិងអន្តរជាតិបានធ្វើកំណត់ហេតុខ្វែងយោបល់គ្នាទាក់ទិននឹងកិច្ចស៊ើបសួរក្នុងសំណុំរឿងទាំងនេះ ។ ទោះជាមានទស្សនៈខុសគ្នាទៅលើបញ្ហាច្បាប់ និងបញ្ហាអង្គហេតុជាក់លាក់មួយចំនួនក៏ដោយ ក៏កិច្ចសហការវិជ្ជាជីវៈរវាងចៅក្រមនៅតែបន្តមានលក្ខណៈប្រសើរដដែល។

១៥ ចាប់តាំងពីការចាប់ផ្តើមកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤មក មានការចុះបំពេញបេសកកម្មជាក់ស្តែងចំនួន២៥២លើក និងធ្វើកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន១៣៥៤។ ជាក់ស្តែងនៅឆ្នាំ២០១៦ បានបំពេញបេសកកម្មចំនួន៥១លើក ដោយធ្វើកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន២៤៥នាក់។ ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៥០៣ ដែលបានដាក់ក្នុងសំណុំរឿងទាំងពីរបច្ចុប្បន្នកំពុងស្ថិតក្រោមការពិនិត្យដើម្បីរៀបចំសេចក្តីសម្រេចទទួលស្គាល់ឬបដិសេធ។

១៦ ការិយាល័យសហចៅក្រមស៊ើបអង្កេតបាននិងកំពុងបុរេសកម្មក្នុងការស្វែងរកវិធីកែលំអ និងវិធីជាក់ស្តែងក្នុងក្របខណ្ឌនីតិវិធីនៃច្បាប់និងវិធាននៃផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីរុករក សក្តានុពលសម្រាប់ពង្រឹងនិងផ្តោតសំខាន់ទៅលើការស៊ើបអង្កេត ទោះជានៅមុនពេលកំណត់នីតិវិធី ដូចមានចែងក្នុងវិធាន៦៦ស្ទួនក៏ដោយ មានន័យតាមពិតទាល់តែដល់ដំណាក់កាលចុងក្រោយ នៃការ ស៊ើបសួរប៉ុណ្ណោះ ប៉ុន្តែបើអនុវត្តដូច្នេះវានឹងយឺតពេលសម្រាប់ធានានូវការស៊ើបសួរឲ្យបានឆាប់រហ័ស និងងាយស្រួល។ វិធីនេះក៏នៅតែប្រកាន់យកហើយដំណើរការទៅមុខ។

១៧ តារាងកំណត់ពេលវេលានៃការស៊ើបអង្កេតដែលកំពុងតែបន្ត ស្ថិតក្រោយឥទ្ធិពលនៃកត្តានានាដូចជា៖ ប្រភេទ និងភាពស្មុគស្មាញនៃរឿងក្តី ចំនួនសាក្សីដែលត្រូវផ្តល់សក្ខីកម្ម ចំនួនបេសកម្មចុះដល់ទីកន្លែង ការមានបុគ្គលិកមានគុណវុឌ្ឍិ និងសមត្ថភាពក្នុងការរក្សាទុកបុគ្គលិកដែលមានបទពិសោធន៍ និងការបង្អាក់ជាក់ស្តែងដល់ការបំពេញកិច្ចស៊ើបសួរនិងវត្តមានរបស់សាក្សី។ ទីតាំង ដាច់ស្រយាលមួយចំនួនយើង មិនអាចទៅបំពេញបេសកកម្មក្នុងកំលុងពេលមួយចំនួនក្នុងរដូវវស្សា។ សាក្សីខ្លះរស់នៅបរទេសដែលធ្វើឲ្យដំណើរការស៊ើបអង្កេតកាន់តែស្មុគស្មាញ។ ការគ្រោងទុកពេលវេលារបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត អាស្រ័យទៅលើកត្តាខាងក្រៅមួយចំនួនដែលខ្លួនមិនអាចគ្រប់គ្រងបានដូចជា ការលាឈប់ ពីការងារ របស់បុគ្គលិកសំខាន់ៗ ថវិកាគ្រប់គ្រាន់សម្រាប់ជ្រើសរើសបុគ្គលិកថ្មីនិងមានគុណវុឌ្ឍិសម្រាប់តំណែងនៅទំនេរ ការបកប្រែ ឯកសារទាន់ពេលវេលា ការបកប្រែផ្ទាល់មាត់គ្រប់គ្រាន់ និងសមត្ថភាពធ្វើប្រតិចារឹក និង ការគាំទ្រទាន់ពេលវេលាពីមន្ត្រីនគរបាលយុត្តិធម៌ ។

១៨ ចំនួនញត្តិដែលដាក់ដោយភាគី និងពេលវេលាដែលតម្រូវដោយអង្គបុរេជំនុំជម្រះដើម្បីចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំក៏ប៉ះពាល់ទៅលើក្របខ័ណ្ឌពេលវេលាដែរ ជាពិសេសគឺដោយអានុភាពនៃដីកាដំណោះស្រាយ ត្រូវដោះស្រាយរាល់កំហុស នីតិវិធីទាំងអស់ នៅក្នុងដំណាក់កាលស៊ើបអង្កេតក្រោមវិធាន៧៦។ អាស្រ័យលើទំហំនិងភាពស្មុគស្មាញនៃញត្តិ ទាំងនោះ គឺអាចអាចត្រូវការពេលវេលាពី២ទៅ៣ខែគិតចាប់ពីពេលដាក់ រហូតដល់ព្រាងសេចក្តី សម្រេចលើកទី១ ។ ក្នុងករណីត្រូវការពេលវេលាបន្ថែមសម្រាប់បណ្តឹងឧទ្ធរណ៍ចំពោះមុខអង្គបុរេជំនុំ ជម្រះ បច្ចុប្បន្នជាមធ្យមគឺត្រូវការពេលវេលា៦ខែ។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជា មុននូវតារាងកំណត់ពេលវេលាអនុវត្តអាចផ្អែកលើបទពិសោធន៍កន្លងទៅនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ហើយមិនអាចចាត់ទុកឲ្យលើសពីការប្រមាណទុកមួយនោះឡើយ។ កត្តាមួយចំនួនដូចរៀបរាប់ខាងលើពិតជាមិនអាចគ្រប់គ្រងបានដោយសហចៅក្រមស៊ើបអង្កេតឡើយ។ ហេតុដូច្នេះ ការកែតម្រូវពេលវេលាគ្រោងទុកផងដែរដែលតម្រូវដោយបរិយាកាសប្រតិបត្តិការជាក់ស្តែង។

១៩ ការិយាល័យសហចៅក្រមស៊ើបអង្កេតទទួលបានអ្នកធ្វើការបន្ថែមពីប្រទេសកាណាដា និងអ្នកហាត់ការជាច្រើនដែលបំពេញការងារយ៉ាងយូរចំនួន០៦ខែ។ ចំនួនបុគ្គលិកបច្ចុប្បន្ននិងការរៀបចំជាក់ស្តែង

ធ្វើឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតងាយរងផលប៉ះពាល់នៅក្នុងករណីដែលបុគ្គលិកទាំងនោះត្រឡប់ទៅវិញ ហើយវាក៏ប៉ះពាល់ ដល់លទ្ធភាពក្នុងការស្រូបយកបន្ទុកកិច្ចការបន្ថែមទៀតផងដែរ ដែលបន្ទុកកិច្ចការ នេះកើតចេញពីការ ដាក់ឯកសារតុលាការរបស់ភាគី និង/ឬ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះ ។ ការលាលែងរបស់បុគ្គលិកមួយចំនួននៅឆ្នាំ២០១៦ ផ្គួបផ្សំជាមួយនឹងរយៈពេលយូរមុននឹង ជ្រើសរើសឡើងវិញ ឃើញថាបានជះឥទ្ធិពលមិនល្អចំពោះកិច្ចការដែលកំពុងតែដំណើរការ។

២០ វិធានផ្ទៃក្នុងបញ្ញត្តិអំពីដំណាក់កាលនីតិវិធីផ្សេងៗ ដែលសហចៅក្រមស៊ើបអង្កេតនឹងអនុវត្តតាម ដើម្បីបំពេញឲ្យបានពេញលេញនូវដំណើរការស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតត្រូវតែស៊ើបអង្កេតអង្គហេតុនានាដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដែលដាក់ដោយសហព្រះរាជអាជ្ញា។ ភាគី អាចស្នើសុំសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរជាក់លាក់មួយចំនួនហើយការណ៍នេះអាចតម្រូវឲ្យមានការកិច្ចការស៊ើបអង្កេតយ៉ាងច្រើន អាស្រ័យទៅលើករណីនោះ។ ការបដិសេធមិនពិចារណាលើសំណើសុំបំពេញកិច្ចស៊ើបសួរអាចនឹងត្រូវបានប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ហើយផ្អែកលើ ពិសោធន៍កន្លងមកគឺថា អង្គជំនុំជម្រះអាចតម្រូវរហូតដល់៦ខែ ឬច្រើនជាងនេះ ដើម្បីសម្រេចទៅលើបណ្តឹងឧទ្ធរណ៍បែបនេះ។ វាអាស្រ័យទៅ លើកម្មវត្ថុ នៃបណ្តឹងឧទ្ធរណ៍ និងលទ្ធផល ដែលសេចក្តីសម្រេចនានាអាចមានផលប៉ះពាល់យ៉ាង ច្រើនទៅលើការស៊ើបអង្កេតដែលកំពុងតែដំណើរការហើយវាបន្ថែមយ៉ាងច្រើនទៅលើពេលវេលាដែល ចាំបាច់ដើម្បីបញ្ចប់កិច្ចការនេះ។ ករណីនេះ ដូចគ្នាទៅនឹងសំណើសុំមោឃភាព នៅអង្គបុរេជំនុំជម្រះ ទាក់ទិននឹង កិច្ចស៊ើបសួរ ដែលមិនរងការចោទប្រកាន់ថាមិនស្របច្បាប់ ពីព្រោះ ថា សហចៅក្រម ស៊ើបអង្កេតមិនមានអំណាចធ្វើមោឃភាពទៅលើកិច្ចស៊ើបសួររបស់ខ្លួនឯងបានឡើយ។

២១ នៅពេលសហចៅក្រមស៊ើបអង្កេតចាត់ទុកការស៊ើបអង្កេតត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់ភាគីទាំងអស់ដែលពេលនោះមានរយៈពេល១៥ថ្ងៃដើម្បីស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមលើកលែងតែភាគីបោះបង់រយៈពេលនោះចោល។ រាល់ការយោងទាំងអស់ទៅលើការបញ្ចប់កិច្ចស៊ើបអង្កេតនៅ ក្នុងគម្រោងបញ្ចប់ផែនការ យោងទៅដល់ ការផុតកាលបរិច្ឆេទក្នុងរយៈពេល១៥ថ្ងៃ ដែលចែងនៅក្នុង វិធាន៦៦(១)នៃវិធានផ្ទៃក្នុង ក្រោយពីការជូនដំណឹងអំពីការបិទបញ្ចប់។

គ្មានវិធីណាមួយគួរជឿទុកចិត្ត ក្នុងការព្យាករពេលវេលាជាក់លាក់ក្នុងការឆ្លើយតបទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួរដែលដាក់នៅក្នុងកំលុងពេលនោះទេ។

២២ ប្រសិនបើសហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធចោលសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម សហចៅក្រមស៊ើបអង្កេតត្រូវតែចេញដីកាសម្រេចមួយដែលមានសំអាងហេតុ។ នៅក្នុងរយៈពេល ៣០ថ្ងៃបន្ទាប់ពីការជូនដំណឹងអំពីដីកាសម្រេចនេះ ភាគីទាំងអស់អាចដាក់បណ្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ ការសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍បែបនេះ គឺអាស្រ័យទៅលើចំនួនបណ្ដឹងឧទ្ធរណ៍ និងពេលវេលាដែលតម្រូវ សម្រាប់អង្គបុរេជំនុំជម្រះ។ ដំណើរការក្នុងផ្នែកនេះអាចតម្រូវឲ្យមានការកែសម្រួលថែមទៀតទៅលើពេលវេលាដែលគ្រោងទុក។ វាមិនអាចទៅរួចទេក្នុងការគ្រោងទុកពេលវេលាជាក់លាក់ទៅលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធមិនទទួលយកសំណើ ប៉ុន្តែដោយផ្អែកលើបទពិសោធន៍កន្លងមក គឺថា វាអាចត្រូវការពេលវេលា៦ខែ ឬច្រើនជាងនេះ ក្នុងករណីនីមួយៗ។

២៣ នៅពេលដែលរយៈពេល៣០ថ្ងៃ បានផុតកំណត់ ត្រូវបានបោះបង់ចោល ឬបណ្ដឹងឧទ្ធរណ៍ដែលបានលើកឡើងខាងលើត្រូវបានជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអាចបញ្ជូនសំណុំរឿងភ្លាមៗទៅឲ្យសហព្រះរាជអាជ្ញា ដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ ហើយក្នុងសំណុំរឿងនេះគឺរយៈពេល៣ខែពីព្រោះបច្ចុប្បន្ននេះពុំទាន់មានជនត្រូវចោទណាម្នាក់ត្រូវបានឃុំខ្លួននៅឡើយទេ។ មេធាវីការពារក្ដីត្រូវតែទទួលបាននូវពេលវេលាគ្រប់គ្រាន់ក្នុងការឆ្លើយតប។ ទាល់តែក្រោយពេលដំណាក់កាលដែលលើកឡើងខាងលើនេះត្រូវបាន បញ្ចប់ទើបសហចៅ ក្រមស៊ើបអង្កេតអាចនឹងចេញដីកាដំណោះស្រាយថាតើត្រូវចោទប្រកាន់ជនត្រូវចោទ ដែលត្រូវបញ្ជូន ជនត្រូវចោទទៅជំនុំជម្រះ ឬត្រូវទម្លាក់ចោលការចោទប្រកាន់។ នៅពេលដែលដីកាដំណោះស្រាយត្រូវបានដាក់ សហចៅក្រមស៊ើបអង្កេតត្រូវអស់អាណាត្តិបំពេញកិច្ចស៊ើបសួរហើយ។

២៤ ការិយាល័យសហចៅក្រមស៊ើបអង្កេតមានបំណងបង្កើតនិងធ្វើឲ្យខ្លីប្រកបដោយខ្លឹមសារចំពោះការធ្វើសេចក្ដីព្រាងដីកាដំណោះស្រាយតាមលទ្ធភាពដែលអាចធ្វើទៅបាន នៅពេលដែលមានលទ្ធភាពនិងយុត្តិកម្មសមស្របនៃសេចក្ដីសម្រេចនោះ។ពេលវេលាគ្រោងទុកសម្រាប់ការធ្វើសេចក្ដីព្រាងដីកាដំណោះស្រាយក្នុងសំណុំរឿង០០១និង០០២ មានរយៈពេលប្រមាណ៣ខែក្នុងសំណុំរឿង០០១ដែលពាក់ព័ន្ធសេនាធិការយោមានកម្រិតមួយ និងមានរយៈពេលប្រមាណ៨ខែចំពោះសំណុំរឿង០០២

01739907

ជាសំណុំរឿងដែលប្រហែលជាផ្ទុះគ្នាជាមួយនឹងសំណុំរឿង០០៤(យឹម ទិត្យ)និងមានលក្ខណៈស្មុគស្មាញដូចគ្នា។ បញ្ហាបកប្រែឲ្យបានទាន់ពេលវេលានឹងជះឥទ្ធិពលជាក់ស្តែងនៅក្នុងដំណាកកាលធ្វើសេចក្តីព្រាងដីកាដំណោះស្រាយ ដែលក្នុងនោះ មិនមែនត្រឹមតែអត្ថបទនៃដីកានឹងត្រូវបកប្រែតែប៉ុណ្ណោះទេ ប៉ុន្តែការបកប្រែទៀតសោតនឹងត្រូវមានការពិនិត្យសេចក្តីយោងជើងទំព័រដាច់ដោយឡែកពីព្រោះទម្រង់នៃសំណៅខុសគ្នាគឺមិនមានលក្ខណៈដូចគ្នាបេះបិតនោះទេ ឧទាហរណ៍ ទាក់ទិននឹងលេខទំព័រជាដើម។ជាងនេះទៀត ចូរកត់សម្គាល់ថា ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលធ្វើការជាមួយនឹងបុគ្គលិកមានចំនួនតិចនោះ គឺធ្វើការលើ៤មុខព្រួញ ដែលតំណាងឲ្យទំហំការងារដ៏ច្រើនរហូតដល់ថ្ងៃចេញដីកាដំណោះស្រាយ។

២៥ កត្តាទាំងនេះបានជះឥទ្ធិពលទៅលើរឿងក្តីនីមួយៗ។ គម្រោងពេលវេលាមិនមានការប្រែប្រួលទេនៅក្នុងកំណែគម្រោងបញ្ចប់ផែនការលើកនេះ លើកលែងតែការពន្យារតិចតួចទៅលើការបិទកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ ដូចមានការពន្យល់ហេតុផលខាងក្រោម។ ក្រោយពីមានការចោទប្រកាន់បន្ថែមនៅក្នុងខែធ្នូឆ្នាំ២០១៥ ការជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ត្រូវបានកំណត់ថានឹងចេញនៅក្នុងត្រីមាសទី៤ឆ្នាំ២០១៦។ ប៉ុន្តែ តម្រូវការចាំបាច់ក្នុងការសម្រេចទៅលើញត្តិសំខាន់ៗ បានបណ្តាលឲ្យមានការពន្យារគម្រោងពេលវេលានេះ។ ការជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរនេះនឹងចេញនៅត្រីមាសទី១ឆ្នាំ២០១៧ លើកលែងតែមានកាលៈទេសៈដែលមិនអាចស្មានទុកបាន[10]។ ក្រោយពីចេញសេចក្តីជូនដំណឹងរួច ដំណើរការនីតិវិធីក្នុងសំណុំរឿង០០៣ប្រឆាំងនឹង មាស មុត នឹងដំណើរការទៅមុខដោយអនុវត្តតាមដំណាក់កាលនីតិវិធីតម្រូវដោយវិធានផ្ទៃក្នុង ដូចរៀបរាប់ខាងលើ។ ដីកាដំណោះស្រាយរំពឹងថានឹងចេញនៅត្រីមាសទី២ឆ្នាំ២០១៧។

២៦ ក្នុងសំណុំរឿង០០៤ មេធាវីការពារក្តី យឹម ទិត្យ ទទួលបានការអនុញ្ញាតឲ្យពិនិត្យមើលសំណុំរឿងនៅខែធ្នូ ឆ្នាំ២០១៥។ ទោះបីជាគេប្រមើលឃើញថានឹងមានញត្តិរបស់មេធាវីការពារក្តី ក៏ការជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរនៅតែរំពឹងថានឹងចេញនៅត្រីមាសទី១ឆ្នាំ២០១៧ បន្ទាប់មកនឹងមានដីកាដំណោះស្រាយចេញនៅត្រីមាសទី៣ ឆ្នាំ២០១៧។

[10] ការជូនដំណឹងនេះចេញនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧។

២៧ នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតបានបង្គាប់ឲ្យបំបែកសំណុំរឿង អ៊ឹម ចែម ពីសំណុំរឿង០០៤ ដោយបង្កើតបានជាសំណុំរឿងលេខ០០៤/០១ ហើយនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០១៦ នឹងបញ្ជូនសំណុំរឿងនេះទៅការិយាល័យសហព្រះរាជអាជ្ញាដើម្បីពិនិត្យមូលនិងចេញដីកាសន្និដ្ឋានស្ថាពរ។ សហព្រះរាជអាជ្ញានិងមេធាវីការពារក្ដីបានដាក់សារណារបស់ខ្លួន ហើយសហចៅក្រមស៊ើបអង្កេតកំពុងតែធ្វើសេចក្ដីព្រាងដីកាដំណោះស្រាយ ដែលនឹងប្រកាសនៅត្រីមាសទី១ ឆ្នាំ២០១៧។

២៨ កិច្ចស៊ើបសួរលើ អោ អាន ត្រូវបានបញ្ចប់ដោយសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ហើយសំណុំរឿងនេះត្រូវបានបំបែកទោជាសំណុំរឿងថ្មី ០០៤/០២។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានចេញផងដែរនូវដីកាមួយអនុលោមតាមវិធាន៦៦ស្ទួន ដោយបន្ថយវិសាលភាពនៃកិច្ចស៊ើបសួរនេះ។ ដីកាដំណោះស្រាយគ្រោងនឹងចេញក្នុងត្រីមាសទី២ ឆ្នាំ២០១៧។

២៩ គម្រោងការរួមដែលបានកែសម្រួលរួចនៅពេលនេះគឺ៖

- កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ នឹងត្រូវបញ្ចប់នៅ ត្រីមាសទី១ ឆ្នាំ ២០១៧[11]។
- ដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣នឹងចេញនៅចុងត្រីមាសទី២ឆ្នាំ២០១៧។
- ដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤/០១ នឹងចេញនៅក្នុងត្រីមាសទី១ ឆ្នាំ២០១៧។
- ដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤/០២ នឹងចេញ ចុងត្រីមាសទី២ ឆ្នាំ២០១៧។
- ការស៊ើបអង្កេតក្នុងសំណុំរឿង០០៤ នឹងបញ្ចប់នៅត្រីមាសទី១ ឆ្នាំ២០១៧។
- ដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ នឹងចេញនៅ ត្រីមាសទី៣ ឆ្នាំ២០១៧។

[11] ការជូនដំណឹងនេះចេញនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧។

## IV. ផែនការបញ្ចប់សវនាការ

៣០ តារាងពេលវេលានៃការបញ្ចប់សវនាការត្រូវកំណត់ដោយកត្តានានាដូចជា៖ លក្ខណៈ និងភាពស្មុគស្មាញនៃសំណុំរឿង បញ្ហាសុខភាពរបស់ជនជាប់ចោទដែលមានវ័យចាស់ជរា ចំនួនសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវកោះហៅ ភាពទំនេរនិងរយៈពេលនៃការធ្វើសក្ខីកម្មរបស់សាក្សីទាំងនោះ ការបង្អាក់ជាក់ស្តែងនានាក្នុងការបំពេញកិច្ចដំណើរការនីតិវិធី ចំនួនញត្តិដាក់ដោយភាគី និងការពិនិត្យពិច័យផ្នែករដ្ឋបាលផ្សេងៗទៀត ក្នុងនោះរួមមានការបកប្រែផ្ទាល់មាត់បានត្រឹមត្រូវ និងការបកប្រែឯកសារទាន់ពេលវេលា។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្តគ្រោងការ គឺផ្អែកលើបទពិសោធន៍កន្លងទៅ ទាំងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងស្ថាប័នតុលាការប្រហាក់ប្រហែលគ្នានេះ។

៣១ ការប្រជុំរៀបចំសវនាការចំនួនមួយ ឬច្រើន តែងតែបានរៀបចំឡើងមុនពេលការចាប់ផ្តើមសវនាការជាក់ស្តែង។ សវនាការចាប់ផ្តើមដោយសវនាការបឋម។ នៅក្នុងសវនាការបឋមនេះ អង្គជំនុំជម្រះសាលាដំបូង ពិចារណាទៅលើបញ្ជីសាក្សីសក្ខីនុពល និងអ្នកជំនាញ ដែលដាក់ជូនដោយភាគីព្រមទាំងអញ្ញត្រកម្ម លើកឡើងដោយភាគី ហើយភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តួចផ្តើមនូវចំណុចជាក់លាក់អំពីសំណងដែលខ្លួនស្នើសុំ។ សវនាការលើអង្គសេចក្តីចាប់ផ្តើមដោយមានការធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបពីសំណាក់សហព្រះរាជអាជ្ញា ហើយជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន មុនពេលអង្គជំនុំជម្រះសាលាដំបូង ចាប់ផ្តើមតាំងសំណួរដល់ជនជាប់ចោទ ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី និងស្តាប់នូវការបង្ហាញភ័ស្តុតាង។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទអង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ក្រោយពេលពិនិត្យភ័ស្តុតាងទាំងអស់រួចហើយ អង្គជំនុំជម្រះស្តាប់ការបិទកិច្ចពិភាក្សាដេញដោលពីសំណាក់ភាគី មុនពេលពិភាក្សាគ្នាជាសម្ងាត់ដើម្បីសម្រេចសេចក្តី។ ប្រសិនបើជនជាប់ចោទត្រូវផ្តន្ទាទោស អង្គជំនុំជម្រះសម្រេចទៅលើទោសសមស្របដែលបានកំណត់នៅក្នុងសាលក្រមរបស់ខ្លួន។ ដោយឈរលើមូលដ្ឋាននៃជំហាននីតិវិធីទាំងនេះទើបយើងកំណត់បាននូវព្រឹត្តិការណ៍សំខាន់ៗផ្សេងៗគ្នាសម្រាប់សវនាការនីមួយៗបាន។

01739910

## ក. <u>សំណុំរឿង០០២/០២</u>

៣២ កិច្ចដំណើរការនីតិវិធីលើភស្តុតាងបានចាប់ផ្ដើមនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ដោយអង្គជំនុំជម្រះត្រូវធ្វើសវនាការចំនួន៣ថ្ងៃក្នុងមួយសប្ដាហ៍។លទ្ធផលនៃការវាយតម្លៃផ្នែកវេជ្ជសាស្ត្ររបស់ជនជាប់ចោទនៅខែមករា ឆ្នាំ២០១៥បង្ហាញថា ការកំណត់៤ថ្ងៃក្នុង១សប្ដាហ៍ជាការសមស្រប ដោយសវនាការពេលព្រឹកធ្វើឲ្យបានខ្លីបន្តិច។ ដូច្នេះអង្គជំនុំជម្រះបានត្រឡប់ទៅអនុវត្តតាមពេលកំណត់៤ថ្ងៃក្នុង១សប្ដាហ៍វិញ នៅខែកុម្ភៈ ឆ្នាំ២០១៥ ដែលជាការពន្លឿនដល់ការជំនុំជម្រះក្ដី។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ អង្គជំនុំជម្រះបានស្ដាប់ សក្ខីកម្មសាក្សីសរុបចំនួន១១៣ ដើមបណ្ដឹងរដ្ឋប្បវេណីសរុបចំនួន ៦៤ និង អ្នកជំនាញចំនួន៨នាក់ នៅលើប្រធានបទសហករណ៍ត្រាំកក់ (ក្នុងនោះរួមមាន មន្ទីរសន្តិសុខក្រាំងតាចាន់ និងការប្រព្រឹត្តិលើជនជាតិចាម) ការដ្ឋានទំនប់១មករា ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម និងការប្រព្រឹត្តិលើជនជាតិចាម និងជនជាតិវៀតណាម មន្ទីរសន្តិសុខអូរកន្សែង និងភ្នំក្រោល និងមន្ទីរសន្តិសុខស២១ ព្រមទាំងការបោសសម្អាតផ្ទៃក្នុង។ បទបញ្ជាឲ្យរៀបអាពាហ៍ពិពាហ៍ លក្ខណៈនៃជម្លោះប្រដាប់អាវុធ និង តួនាទីរបស់ជនជាប់ចោទ។

៣៣ កាលពីដំបូង អង្គជំនុំជម្រះគ្រោងនឹងបញ្ចប់សវនាការលើភស្តុតាងនៅចុងត្រីមាសទី៤ឆ្នាំ២០១៦។ ប៉ុន្តែជាក់ស្ដែងគឺត្រូវការពេលវេលាបន្ថែមក្នុងការរៀបចំការផ្ដល់សក្ខីកម្មរបស់សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានជ្រើសរើស ហើយទឹកលិចជុំវិញបរិវេណ អ.វ.ត.ក បានបង្ខំ ឲ្យអង្គជំនុំជម្រះផ្អាកសវនាការនៅសប្ដាហ៍ទី១ខែតុលាឆ្នាំ២០១៦។ ខណៈដែលការដាក់បង្ហាញឯកសារពីសំណុំរឿង០០៣ និងសំណុំរឿង០០៤ ទៅក្នុងសំណុំរឿង០០២/០២ ប្រព្រឹត្តទៅពេញមួយឆ្នាំ២០១៦ និងរំពឹងថានឹងបន្តនៅឆ្នាំ២០១៧ទៀត ដោយសារការិយាល័យសហព្រះរាជអាជ្ញានៅតែមានកាតព្វកិច្ចបង្ហាញភស្តុតាងដោះបន្ទុករហូតដល់ចុងបញ្ចប់សវនាការនោះ ការកំណត់កាលបរិច្ឆេទពីសំណាក់អង្គជំនុំជម្រះសម្រាប់ការទទួលយកភស្តុតាងថ្មីអនុលោមតាមវិធាន៨៧(៤) គឺបានកាត់បន្ថយផលប៉ះពាល់ទៅលើការដាក់បង្ហាញឯកសារទាំងនេះ។ ផ្អែកលើមូលដ្ឋានខាងលើនេះ អង្គជំនុំជម្រះគ្រោងបញ្ចប់នីតិវិធីលើភស្តុតាងនៅត្រីមាសទី១ ឆ្នាំ២០១៧[12]។

[12] អង្គជំនុំជម្រះបានបញ្ចប់សវនាការលើភស្តុតាងនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ (សូមមើលសេចក្ដីប្រកាសព័ត៌មាននៅថ្ងៃដដែល)។

៣៤ ដើម្បីរៀបចំការបិទដំណើរការនីតិវិធី អង្គជំនុំជម្រះបានធ្វើកិច្ចប្រជុំរៀបចំសវនាការនៅខែធ្នូ ដើម្បីស្តាប់សារណាពាក់ព័ន្ធនឹងសារណាបញ្ចប់ការដេញដោល និងសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលក្នុងចំណោមបញ្ហាដទៃៗទៀត។ ដោយកត់សម្គាល់បញ្ហាចម្បងៗលើកឡើងដោយភាគី ជាពិសេសរយៈពេលវែងខុសពីធម្មតា និងភាពស្មុំគស្មាញនៃរឿងក្តី អង្គជំនុំជម្រះក៏កំណត់កាលបរិច្ឆេទសម្រាប់ដាក់សារណាសវនាការនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ និងការចាប់ផ្តើមសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧ ហើយបន្ទាប់មកនឹងពិចារណាសម្រេច និងរៀបចំសាលក្រមលើរឿងក្តីនេះ។ គម្រោងពេលវេលានឹងកែសម្រួលទៅតាមជាក់ស្តែង។

៣៥ កត្តាដទៃៗទៀត ដែលបន្តពាក់ព័ន្ធទៅនឹងរយៈពេលជំនុំជម្រះក្តីដែលស្មានទុកដែលអាចកើត ឡើងនៅពេលអនាគត រួមមានការប្រែប្រួលសុខភាពរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះសាលាដំបូងកំពុងតែតាមដានស្ថានភាពសុខភាពរបស់ជនជាប់ចោទជាប្រចាំ។ សម្បទារបស់ជនជាប់ចោទក្នុងការបន្តចូលរួមក្នុងនីតិវិធីសវនាការត្រូវបានវាយតម្លៃនៅចុងខែកក្កដាឆ្នាំ២០១៦ ហើយពិនិត្យឃើញថាជនជាប់ចោទទាំងពីរមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។ ប៉ុន្តែ របាយការណ៍វេជ្ជសាស្ត្រកត់សម្គាល់ឃើញស្ថានភាពសុខភាពមួយចំនួនដែលជនរងគ្រោះទទួលរង ហើយបានលើកអនុសាសន៍ថាមុខងារសតិបញ្ញារបស់ជនជាប់ចោទត្រូវការវាយតម្លៃរៀងរាល់ត្រីមាស។

៣៦ កត្តាថ្មីចំនួន២ដែលបានលើកឡើងដោយមេធាវីការពារក្តីនៅក្នុងកិច្ចប្រជុំរៀបចំសវនាការក្នុងខែធ្នូ ឆ្នាំ២០១៦ ដែលនឹងជះឥទ្ធិពលលើរយៈពេលសវនាការនោះគឺ ការពិនិត្យឡើងវិញទៅលើប្រតិចារឹកសវនាការនិងការផ្តល់ការបកប្រែជាភាសាបារាំងសម្រាប់សាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង០០២/០១ ឲ្យបានទាន់ពេលវេលាដើម្បីឲ្យក្រុមមេធាវីការពារក្តីរៀបចំសារណាបញ្ចប់ការពិភាក្សាដេញដោល។ អង្គជំនុំជម្រះសាលាដំបូងពីមុនបានបញ្ជាក់ជូនការិយាល័យរដ្ឋបាលនូវការព្រួយបារម្ភមួយចំនួនដែលអាចបណ្តាលឲ្យមានការពន្យារពេលវេលាជាចាំបាច់ក្នុងការចេញសាលក្រម ជាអាទិ៍ការផ្តល់សំណៅបកប្រែនិងប្រតិចារឹកស្ពាតរ និង ការបំពេញតំណែងដែលនៅទំនេរ។ ហេតុដូច្នេះ ដោយសារភាពស្មុគស្មាញនៃសំណុំរឿង០០២/០២ ឥទ្ធិពលទៅលើសាលដីកានៅក្នុងសំណុំរឿង០០២/០១ ពេលវេលាដែលត្រូវបញ្ចប់ការបកប្រែនិងប្រតិចារឹក និងបំពេញតំណែងបុគ្គលិក

អង្គជំនុំជម្រះយល់ឃើញ ចាំបាច់ត្រូវពន្យារពេលវេលាសម្រាប់ចេញសាលក្រមក្នុងសំណុំរឿង ០០២/០២។ រយៈពេលដែល ត្រូវពន្យារគឺកំពុងវាយតម្លៃ ដូច្នេះកំណែលើកនេះពុំមានការប្រែប្រួលទេ។

## ខ. បទចោទដែលនៅសេសសល់/ការចោទប្រកាន់តាមអង្គហេតុ ក្នុងសំណុំរឿង០០២

៣៧ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូល ប្រកាសផ្អាកដំណើរការនីតិវិធីពាក់ព័ន្ធនឹងបទចោទដែលនៅសល់ ដែលស្ថិតនៅក្រៅវិសាលភាពនៃ សំណុំរឿង០០២/០១ និង ០០២/០២ ដោយរង់ចាំសេចក្តីសម្រេចសមស្រប របស់អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះតុលាការកំពូលលើកឡើងម្តងទៀតថាអង្គជំនុំជម្រះសាលាដំបូងមានករណីកិច្ចកាត់សេចក្តី ឬចេញសេចក្តីសម្រេចទៅលើបទចោទដែលនៅសល់ក្នុងសំណុំរឿង០០២ អនុលោមតាមក្រមខ័ណ្ឌគតិយុត្តិ និងជំរុញឲ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តទៅតាមករណីកិច្ចនេះ។ ដោយបានទទួលសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើបញ្ចប់បទចោទដែលនៅសេសសល់ ក្នុងសំណុំរឿង ០០២អង្គជំនុំជម្រះសាលាដំបូងបានកំណត់សវនាការ លើបទចោទ/អង្គហេតុដែលបានចោទប្រកាន់ដែលនៅសេសសល់ក្នុងសំណុំរឿង០០២ដែលនឹងត្រូវប្រព្រឹត្តទៅភ្លាមៗក្រោយពីការបញ្ចប់សវនាការលើភស្តុតាងក្នុងសំណុំរឿង០០២/០២[13]។

## គ. សំណុំរឿង០០៣ និង សំណុំរឿង០០៤

៣៨ លុះត្រាតែមានសេចក្តីសម្រេចថាតើ សំណុំរឿង០០៣ និង/ឬ០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ បើមិនដូច្នោះទេយើងមិនអាចស្មានទុកបានទៅលើរយៈពេលសម្រាប់បញ្ចប់ការជំនុំជម្រះក្តីទាំងនេះបានឡើយ។ ការវាយតម្លៃលើពេលវេលាដែលតម្រូវ អាចផ្អែកទៅលើចំនួនចុងចោទ ភាពស្មុគស្មាញនៃ អង្គហេតុ និងអង្គច្បាប់នៃបទចោទ ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

---

[13] សវនាការធ្វើឡើងនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ ហើយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនឹងចេញនៅក្នុងពេលវេលាសមស្រប (សូមមើលសេចក្តីប្រកាសព័ត៌មាន ថ្ងៃដដែល)។

## V. ផែនការបញ្ចប់បណ្តឹងសាទុក្ខ

### ក. សំណុំរឿង០០២/០១

៣៩ នៅថ្ងៃទី២៣ ខែវិច្ឆិកា អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសដីកាលើបណ្តឹងសាទុក្ខនៅ ឆមាស ទី២ ឆ្នាំ២០១៤ ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២/០១។ ប្រការនេះបានបញ្ចប់ដំណើរការនីតិវិធីតុលាការក្នុងសំណុំរឿង០០២/០១។

### ខ. សំណុំរឿង០០២/០២

៤០ អង្គជំនុំជម្រះតុលាការកំពូលព្យាករណ៍នៅពេលនេះថា បណ្តឹងសាទុក្ខ(មួយឬច្រើន)ប្រសិនបើ ដាក់ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០២ នឹងមានចំនួនតិច បំផុតដោយសារពេលវេលានិងធនធាន ដូចក្នុងសំណុំរឿង០០២/០១ដែរ។ រហូតទាល់តែចេញសាលក្រមក្នុងសំណុំរឿង០០២/០២ ទើបមានលទ្ធភាពសម្រាប់ភាគីដាក់បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿងនោះ ដែលត្រូវតែសម្រេចនៅក្នុងពេលរយៈពេល៣ខែកំណត់ដោយច្បាប់(ពន្យារ៤ខែក្នុងករណីពិសេស)។

### គ. សំណុំរឿង០០៣/០០៤

៤១ ប្រសិនបើសំណុំរឿង០០៣ និង/ឬ ០០៤ បន្តទៅមុខរហូតដល់ដំណាក់កាលជំនុំជម្រះ នោះ បណ្តឹងឧទ្ធរណ៍ភ្លាមៗឬបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងទំនងជាកើតឡើង។ ទោះជាយ៉ាងណាក៏ដោយ ដោយហេតុថាយើងមិនដឹងថាសំណុំរឿងណាមួយដំណើរការរហូតដល់ដំណាក់កាលជំនុំជម្រះ និងមិនដឹងពីបទចោទណាខ្លះនោះវាហាក់ដូចជាឆាប់ពេកក្នុងការផ្តល់ នូវការប៉ាន់ស្មានចំពោះពេលវេលាដែលតម្រូវក្នុងការសម្រេចលើបណ្តឹងសាទុក្ខណានៃសំណុំរឿងពាក់ព័ន្ធ។

01739914

## VI. សេចក្តីសន្និដ្ឋាន

៤២ សម្រាប់ឆ្នាំ២០១៦ គេរំពឹងថា ព្រឹត្តិការណ៍ចំនួន១នឹងត្រូវសម្រេចបានក្នុងសំណុំរឿង០០២/០១ ដោយមានការចេញសាលដីកាក្នុងសំណុំរឿងនេះ។ ចំពោះសំណុំរឿង ០០៤ គឺ សម្រេចបានព្រឹត្តិការណ៍ចំនួន១ដោយមាន សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ ទាក់ទិននឹង អោ អាន។

៤៣ សម្រាប់ឆ្នាំ២០១៧មានការរំពឹងថានឹងសម្រេចបាននូវព្រឹត្តិការណ៍សំខាន់ចំនួន៣ក្នុងសំណុំរឿង០០២/០២ ពោលគឺ៖ (i) ការបញ្ចប់សវនាការលើកស្តុតាង (ii)ការបញ្ចប់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល និង ការចេញសាលក្រមក្នុងសំណុំរឿងនោះ។ ក្នុងសំណុំរឿង០០៣ និង ០០៤ រំពឹងថានឹងសម្រេច បានគ្រោង ការសំខាន់ចំនួន ៥ គឺ (i) ការជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ពាក់ព័ន្ធ មាស មុត (ii)ការចេញដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៣ជាមួយនឹងសេចក្តីសម្រេច របស់ អង្គបុរេជំនុំជម្រះថាតើត្រូវបញ្ជូនសំណុំរឿងទាំងនេះទៅជំនុំជម្រះឬបញ្ចប់កិច្ចនីតិវិធី (iii) ការចេញ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ (iv) ការចេញដីការដំណោះស្រាយ ក្នុងសំណុំរឿង០០៤/០១ ប្រឆាំង អ៊ឹម ចែម និង ការចេញដីកា ដំណោះស្រាយ ក្នុងសំណុំរឿង០០៤/០២ប្រឆាំងនឹង អោ អាន ជាមួយនឹងសេចក្តីសម្រេច របស់អង្គបុរេជំនុំជម្រះថាតើត្រូវបញ្ជូនសំណុំរឿងទាំងនេះទៅជំនុំជម្រះឬបញ្ចប់កិច្ចនីតិវិធី (v) ការចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤/០១ ប្រឆាំងនឹង អ៊ឹម ចែម និង សំណុំរឿង០០៤/០២ ពាក់ព័ន្ធនឹង អោ អាន ជាមួយនឹង សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះថាតើត្រូវបញ្ជូនសំណុំរឿងទាំងនេះទៅជំនុំជម្រះឬបញ្ចប់កិច្ចនីតិវិធី។ ក្នុងករណីដែលសំណុំរឿងណាមួយ ត្រូវបានបញ្ជូនទៅជំនុំជម្រះទាំងមូល ឬដោយផ្នែកការព្យាករទុកនូវតារាងកំណត់ពេលវេលាក្នុងសំណុំរឿងទាំងនេះគឺអាចយកមកវាយតម្លៃបាន។

៤៤ សម្រាប់ឆ្នាំ ២០១៨ មានការរំពឹងទុកថានឹងសម្រេចបានព្រឹត្តិការណ៍សំខាន់ចំនួន១ ក្នុងសំណុំរឿង០០២/០២។ កាលបរិច្ឆេទចុងក្រោយសម្រាប់បណ្តឹងសាទុក្ខ។ ទាក់ទិន នឹងសំណុំរឿង០០៤ រំពឹងថានឹងមានព្រឹត្តិការណ៍សំខាន់មួយថែមទៀត(i) ការចេញសេចក្តី សម្រេចទៅ លើបណ្តឹងឧទ្ធរណ៍ ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ ពាក់ព័ន្ធ យឹម ទិត្យ ជាមួយនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះថាតើត្រូវបញ្ជូនសំណុំរឿងទាំងនេះទៅជំនុំជម្រះឬបញ្ចប់កិច្ចនីតិវិធី។

៤៥ សម្រាប់ឆ្នាំ២០១៩ មានការរំពឹងថានឹងសម្រេចបាននូវព្រឹត្តិការណ៍សំខាន់ចំនួន១ គឺ ៖ (i) ការចេញសាលដីកាលើសំណុំរឿង០០២/០២។

៤៦ ក្នុងករណីដែលសំណុំរឿង០០៣ និង សំណុំរឿង០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ ទាំងមូលឬដោយផ្នែក គម្រោងពេលវេលាអាចព្យាករណ៍បាន។

៤៧ ការស្មានទុកនូវព្រឹត្តិការណ៍សំខាន់ៗ ដែលរៀបរាប់ខាងលើនេះ មានសង្ខេបជូនក្នុងតារាងដែលភ្ជាប់ជូនជាមួយនឹងផែនការនេះស្រាប់។

# តារាងកំណត់ពេលវេលាតាមការគ្រោងទុកដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ




(ក) ការបញ្ចប់សវនាការលើបណ្ដឹងសាទុក្ខ

(ខ) ការប្រកាសសាលដីកា




(គ) ការបញ្ចប់សវនាការលើភស្តុតាង

(ឃ) សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល

(ង) សាលក្រម

(ច) កាលបរិច្ឆេទកំណត់សម្រាប់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម

(ឆ) សាលដីកា




(ជ) ការជូនដំណឹងអំពីការបញ្ចប់ការស៊ើបអង្កេត

(ឈ) ដីកាដំណោះស្រាយ គសចស

(ញ) សេចក្ដីសម្រេចរបស់ អបជ ទៅលើដីកាដំណោះស្រាយ